Swiss Water & Sanitation Consortium

CARITAS Schweiz Suisse Svizzera Svizra

# សាលាបៃតង - សេចក្តីសង្ខេប

## ភ្ជាប់ការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យក្នុងសាលារៀន..... ជាមួយការបណ្តុះបណ្តាល និងអនុវត្តបរិស្ថានល្អ។

**គាំទ្រដោយ:** ភ្នាក់ងារស្វីសដើម្បីការអភិវឌ្ឍន៍ និងសហប្រតិបត្តិការ (SDC); សម្ព័ន្ធស្វីស ដើម្បីទឹកស្អាត និងអនាម័យ(SWSC); Terre des hommes; ការីតាសស្វីស; HELVETAS; Eawag; IRHA.





## តើអ្វីទៅជាសាលាបៃតង

សាលាបៃតងគឺជាសាលាដែលមាន **ផាសុខភាពល្អ និងបរិស្ថានល្អ** ។
វាផ្តល់នូវបរិយាកាសរៀនសូត្រប្រកបដោយផាសុកភាពនិងបង្ហាញអោយសិស្សានុសិស្សទទួលបាននូវបច្ចេកវិទ្យានិងការអនុវត្តន៍ដែលមិនប៉ះពាល់ដល់បរិស្ថាន
ដែលអាចយកជាគំរូទៅអនុវត្តនៅក្នុងសហគមន៍របស់ពួកគេ។
ដើម្បីក្លាយជាសាលាបៃតងគឺជាដំណើរការជាជំហាន ។ ចំណុចចាប់ផ្តើមគឺដើម្បីធានាថាកុមារបរិភោគទឹកមានសុវត្ថិភាព ប្រើប្រាស់បង្គន់អនាម័យនិងចេះថែរក្សា និងមានការអនុវត្តអនាម័យឱ្យល្អ។

នៅពេលដែលបានសំរេចបានហើយ **សាលាបៃតងមានសកម្មភាពលើសពីទឹកស្អាត និងអនាម័យ**
និងដែលផ្តោតលើអនាម័យនិងសុខភាពកំឡុងពេលមករដូវ
សកម្មភាពក្នុងការរៀបចំសួនដំណាំក្នុងសាលារៀន
ការគ្រប់គ្រងកាកសំណល់រឹងអោយមានសុវត្ថិភាព និងការអនុវត្តបរិស្ថានល្អ។
សម្រាប់សាលាបៃតង
កុមាររៀនជុំវិញប្រធានបទសាលាបៃតងទាំងអស់ដោយ ការអនុវត្ត និងការធ្វើពិសោធន៍។



## តើសម្ភារៈសាលាបៃតងមានអ្វីខ្លះ?

### សម្ភារៈសាលាបៃតងរួមមានៈ

- **សៀវភៅណែនាំបច្ចេកវិទ្យា៖**ចងក្រងឧទាហរណ៍នៃជម្រើសបច្ចេកវិទ្យាដែលងាយស្រួលអនុវត្តតាម និងចំណាយថវិការតិច។
- **សៀវភៅណែនាំពីលំហាត់ជាក់ស្តែង៖**មានសកម្មភាពដែលគ្រូអាចប្រើដើម្បីបំពេញមេរៀនទ្រឹស្តីដែលងាយស្រួលរកសម្ភារៈ និងចំណាយថវិការតិច។
- **មគ្គុទេសក៍សម្រាប់អ្នកសម្របសម្រួល៖** សង្ខេបពីការអនុវត្តន៍ជាក់ស្តែងដែលគ្រូអាចប្រើសម្រាប់ប្រធានបទនីមួយៗនៃសាលាបៃតង។

សម្ភារៈទាំងនេះមានគោលបំណងជម្រុញលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធរបស់សាលារៀនក្នុងមាគ៌ាឆ្ពោះទៅរកការក្លាយជាសាលាបៃតង។ សម្ភារៈទាំងនេះត្រូវបានរៀបចំឡើងនៅក្នុងប្រធានបទផ្សេងៗគ្នា៖

- **ប្រធានបទទាក់ទងនឹងទឹកស្អាត និងអនាម័យ៖** ការបរិភោគទឹកមានសុវត្ថិភាព អនាម័យនិងអនាម័ខ្លួនប្រាណ អនាម័យនិងសុខភាពកំឡុងពេលមករដូវ។
- **ប្រធានបទទាក់ទងនឹងបរិស្ថាន៖** បច្ចេកទេសក្នុងការគ្រប់គ្រងដី និងទឹក ដើម្បីអនុវត្តលើសួនបន្លែ ការគ្រប់គ្រងសំណល់រឹងអោយមានសុវត្ថិភាព ផ្ទៃរងទឹកភ្លៀង និងវដ្តទឹក ។ល។



ទឹកដែលខ្ញុំបរិភោគ | អនាម័យ និងអនាម័យខ្លួនប្រាណ | ការលូតលាស់ និងការប្រែប្រួល

ពីដីក្លាយជាអាហារ ពីសម្រាមក្លាយជាធនធាន

## គម្រោងសាលាបៃតង នៅកម្ពុជា

នៅឆ្នាំ ២០១៩ អង្គការការីតាសស្វីសក្រោមកិច្ចសហការជាមួយអាជ្ញាធរខេត្ត អង្គការស៊ីដូ និង អា.សេ.ដូ បានសាកល្បងអនុវត្តសាលារៀនបៃតងលើសាលា ចំនួន ៨ ក្នុងខេត្តបន្ទាយមានជ័យ។ វិធីសាស្ត្រនេះបាននាំឱ្យមានភាពប្រសើរឡើងពិតប្រាកដនៅក្នុងបរិយាកាសិក្សានៅសាលារៀន។ វិធីសាស្ត្រនេះបច្ចុប្បន្នកំពុងត្រូវបានពង្រីកលើសាលាចំនួន ៤៥ ដោយមានការសហការជាមួយមន្ទីរអប់រំយុវជននិងកីឡា អង្គការស៊ីដូ និងក្រុមការងារទឹកស្អាត និងអនាម័យជនបទ (RWST)។

សម្ភារៈសាលាបៃតងអាចទទួលបានរយៈ៖**http://waterconsortium.ch/blueschool/**

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

ឃីន ស៊ាងហាក់, seanghak@caritas.ch

វីដេអូពីសាលាបៃតង៖
https://m.facebook.com/100003165870748/posts/2368530629929110?sfns=mo

